**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាឧទ្ធរណ៍ភ្នំពេញ

**សំណុំរឿងព្រហ្មទណ្ឌ**
លេខ ១៦០
ចុះថ្ងៃទី០២.០២.២០២៣
**សាលដីកា**
លេខ ៦៥ "ក្រVII.គ.ឆ"
ចុះថ្ងៃទី១៩-០៦-២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ភ្នំពេញ នាថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣ ដោយមាន៖

**សមាសភាពក្រុមប្រឹក្សា**

លោក [redacted] ជាប្រធាន
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

កញ្ញា [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌលេខ ១៦០ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២៣ ដែលមាន៖

១-ជនជាប់ចោទឈ្មោះ [redacted] សារន់ ភេទប្រុស អាយុ ៥១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ ប្រធានការិយាល័យ ទីកន្លែងកំណើតនៅភូមិ[redacted]ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិ[redacted]ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted]"ស្លាប់" ម្តាយឈ្មោះ [redacted] "ស្លាប់" ប្រពន្ធឈ្មោះ [redacted]មានកូន ០៣នាក់ ជានីតិជន ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

២-ជនជាប់ចោទឈ្មោះ [redacted]សុខុម ភេទប្រុស អាយុ ៥៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមន្ត្រីរាជការ ទីកន្លែងកំណើតនៅភូមិ[redacted]ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិ[redacted] ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted] "ស្លាប់" ម្តាយឈ្មោះ [redacted] "ស្លាប់" ប្រពន្ធឈ្មោះ [redacted]មានកូន ០២នាក់ ជានីតិជន ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

ជាប់ចោទពីបទ៖ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅចំណុចភូមិចំការចេក១ ឃុំក្រញូង និងភូមិព្រៃទួលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី៣០ ខែមាសា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ ។





Scanned with CamScanner

១-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីអ៊ុយ ភេទប្រុស កើតឆ្នាំ១៩៦០ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន នៅផ្ទះលេខ [redacted] រាជធានីភ្នំពេញ ។

២-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពុង ភេទប្រុស កើតឆ្នាំ១៩៥៦ ជនជាតិខ្មែរមានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ [redacted] រាជធានីភ្នំពេញ ។

៣-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វ៉ាន់យូ ភេទប្រុស កើតឆ្នាំ១៩៥៤ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ [redacted] រាជធានីភ្នំពេញ ។

៤-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អេង ភេទស្រី កើតឆ្នាំ១៩៥៧ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិ [redacted] ខេត្តត្បូងឃ្មុំ ។

ដោយមានលោកស្រី [redacted] ណារី ជាមេធាវីការពារតំណាងដោយអាណត្តិ។

## **ឯរឿងហេតុមានដូចតទៅ**

កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ និងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ឈ្មោះ [redacted] **វចនា** ឈ្មោះ [redacted] **សារន់** ឈ្មោះ [redacted] **សុខុម** និងឈ្មោះ [redacted] **សុវណ្ណ** បានចុះកិច្ចព្រមព្រៀងលក់ទិញដីជាមួយដើមបណ្តឹងឈ្មោះ [redacted] **ស្រីអ៊ុយ** ឈ្មោះ [redacted] **ពុង** ឈ្មោះ [redacted] **វ៉ាន់យូ** និងឈ្មោះ [redacted] **អេង** លើផ្ទៃដីសរុបចំនួន ៤១០,៤៦ (បួនរយដប់ក្បៀសសែសិបប្រាំមួយ) ហិកតា ដែលមានទីតាំងទី១ មានទំហំសរុប ២៣១,៤១ (ពីររយសាមសិបមួយក្បៀសសែសិបមួយ) ហិកតា មានទីតាំងស្ថិតនៅភូមិចំការចេក១ ឃុំក្រញូង ស្រុកកំចាយមារ ខេត្តព្រៃវែង និងទីតាំងទី២ មានទំហំ ១៧៩,០៥ (មួយរយចិតប្រាំបួន ក្បៀសសូន្យប្រាំ) ហិកតា មានទីតាំងស្ថិតនៅភូមិព្រៃទួលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង តាមតម្លៃដែលបានឯកភាពដូចនៅក្នុងកិច្ចព្រមព្រៀង។ ចាប់តាំងពីថ្ងៃចុះកិច្ចព្រមព្រៀងលក់ទិញដីលើកទី១ រហូតមកដល់ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ ភាគីអ្នកលក់ទាំងបួននាក់ដែលមានឈ្មោះ [redacted] **វចនា** ឈ្មោះ [redacted] **សុខុម** ឈ្មោះ [redacted] **សារន់** និងឈ្មោះ [redacted] **សុវណ្ណ** បានទទួលប្រាក់ជាបន្តបន្ទាប់ពីភាគីអ្នកទិញ ដែលមានឈ្មោះ [redacted] **ស្រីអ៊ុយ** ឈ្មោះ [redacted] **ពុង** ឈ្មោះ [redacted] **វ៉ាន់យូ** និងឈ្មោះ [redacted] **អេង** សរុបចំនួន ២.០៣១.៣៨២ (ពីរលានសូន្យសែនបីម៉ឺនមួយពាន់បីរយប៉ែតសិបពីរ) ដុល្លារអាមេរិក រួចហើយ តែភាគីអ្នកលក់ពុំមានដីប្រគល់ឱ្យភាគីអ្នកទិញឡើយ។

**-បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ **២៧៣៨ "ល" ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២** របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-កែប្រែបទចោទលើជនជាប់ចោទឈ្មោះ [redacted] **វចនា** ភេទប្រុស អាយុ ៣៩ឆ្នាំ ឈ្មោះ [redacted] **សារន់** ភេទប្រុស អាយុ ៥១ឆ្នាំ ឈ្មោះ [redacted] **សុខុម** ភេទប្រុស អាយុ ៥៤ឆ្នាំ និងឈ្មោះ [redacted] **សុវណ្ណ** ភេទប្រុស អាយុ២៩ឆ្នាំ (អត្តសញ្ញាណខាងលើ) ពីបទ **ឆបោក** ប្រព្រឹត្តនៅចំណុចភូមិចំការចេក១ ឃុំក្រញូង និងភូមិព្រៃទួលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ទៅជាបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្ត



Scanned with CamScanner

នៅចំណុចភូមិចំការចេក១ ឃុំក្រញូងនិងភូមិព្រៃខ្វលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង កាលពីអំឡុងថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

២-ផ្តន្ទាទោសជនជាប់ចោទ៖

២.១-ឈ្មោះ [redacted] រចនា ភេទប្រុស អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ

២.២-ឈ្មោះ [redacted] សុវណ្ណ ភេទប្រុស អាយុ ២៩ឆ្នាំ ជនជាតិខ្មែរ

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០១ (មួយ) ឆ្នាំ ពីបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅចំណុចភូមិចំការចេក១ ឃុំក្រញូង និងភូមិព្រៃខ្វលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង កាលពីអំឡុងថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

២.៣-ឈ្មោះ [redacted] **សារ៉ន់** ភេទប្រុស អាយុ ៥១ឆ្នាំ ជនជាតិខ្មែរ

២.៤-ឈ្មោះ [redacted] **សុខុម** ភេទប្រុស អាយុ ៥៤ឆ្នាំ ជនជាតិខ្មែរ

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០១ (មួយ) ឆ្នាំ **តែទោសនេះត្រូវព្យួរធម្មតា** ពីបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅចំណុចភូមិចំការចេក១ ឃុំក្រញូង និងភូមិព្រៃខ្វលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង កាលពីអំឡុងថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ មាត្រា ៣៩២ មាត្រា ១០៦ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ។

៣-បង្គាប់ឱ្យឈ្មោះ [redacted] **រចនា** ភេទប្រុស អាយុ ៣៩ឆ្នាំ ឈ្មោះ [redacted] **សារ៉ន់** ភេទប្រុស អាយុ ៥១ឆ្នាំ ឈ្មោះ [redacted] **សុខុម** ភេទប្រុស អាយុ ៥៤ឆ្នាំ និងឈ្មោះ [redacted] **សុវណ្ណ** ភេទប្រុស អាយុ២៩ ឆ្នាំរួមគ្នាសងសំណងដូចខាងក្រោម៖

៣.១-ការខូចខាតជាប្រាក់ចំនួន ២.០៣១.៣៩២ (ពីរលានសូន្យសែនបីម៉ឺនមួយពាន់បីរយប៉ែតសិបពីរ) ដុល្លារអាមេរិក

៣.១-ជំងឺចិត្តជាប្រាក់ចំនួន ៦០០.០០០.០០០ (ប្រាំមួយរយលាន) រៀល

ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ស្រ៊ីអ៊ុយ** ឈ្មោះ [redacted] **ឥុង** ឈ្មោះ [redacted] **វ៉ាន់យូ** និងឈ្មោះ [redacted] **អេង** តាមបញ្ញត្តិមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ច្រានចោលការទាមទារលើសពីនេះ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២២ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **រចនា** ឈ្មោះ [redacted] **សារ៉ន់** ឈ្មោះ [redacted] **សុខុម** និងឈ្មោះ [redacted] **សុវណ្ណ** ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ស្រ៊ីអ៊ុយ** ឈ្មោះ [redacted] **ឥុង** ឈ្មោះ [redacted] **វ៉ាន់យូ** ឈ្មោះ [redacted] **អេង** និងប្រកាសជាសាធារណៈ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២។

ភាគីមានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។



Scanned with CamScanner

-បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ១៣០៣ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២២ របស់ អធិបញ្ញារបស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៧៣៨ "ល"ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច: ២-៣ និង ២-៤ នៃសេចក្តីសម្រេចពុំគប្បីសម្រេចការផ្តន្ទាទោសព្យួរឡើយ។ត្រូវអនុវត្តទោសដោយគ្មានការព្យួរទោស។

-បានឃើញ របាយការណ៍រឿង ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ។

-បានឃើញ សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] សារន់, [redacted] សុខុម (អវត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីអ៊ុយ, [redacted] តុង, [redacted] វ៉ាន់ឃួ, [redacted] អេង (អវត្តមាន)

-លោកស្រី [redacted] ណារី ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្តឹងរដ្ឋប្បវេណី (វត្តមាន)

-ប្រធានក្រុមប្រឹក្សា អានរបាយការណ៍សង្ខេបរឿង

-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] សារន់ បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ ខ្លួនបានចូលរួមជាក្រុមក្នុងការទិញដីឲ្យក្រុមហ៊ុនជាមួយឈ្មោះ [redacted] រចនា ដែរដោយគ្រាន់តែឈរឈ្មោះ ហើយខ្លួនពុំបានចុះទៅវាស់វែង ឬទៅធ្វើការទិញពីម្ចាស់ដីផ្ទាល់ទេ ខ្លួនគ្រាន់តែធ្លាប់បានទៅទទួលសែកពីក្រុមហ៊ុនប៉ុណ្ណោះ ។ ចំនួនលុយសរុបដែលក្រុមហ៊ុនទូទាត់ឲ្យជាសែកសរុបប្រហែល ២លានដុល្លារ ដោយតម្រូវឲ្យទិញដីជាង៣០០ហិកតាពេលនោះគឺ១ហិកតា ៤៥០០ដុល្លារ តែការទិញជាក់ស្តែងបានតែប្រហែល ១០៧ ហិកតាប៉ុណ្ណោះក៏អស់លុយ ។ ខ្លួនពុំដឹងថាឈ្មោះ ម៉ាន់ រចនា យកលុយទៅធ្វើអ្វីខ្លះទើបអស់នោះទេ ព្រោះគាត់ជាអ្នកគ្រប់គ្រងសែកដែលក្រុមហ៊ុនបើកឲ្យ។ មូលហេតុដែលទិញដីមិនគ្រប់តាមកិច្ចព្រមព្រៀងដោយការតែដីឡើងថ្លៃជាបន្តបន្ទាប់ហើយម្ចាស់លុយក៏បានឯកភាពទិញតាមលុយនោះដែរ ។

-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] សុខុម បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ ឈ្មោះ [redacted] រចនា បានបបួលខ្លួនឲ្យចូលរួមរៀបចំទិញដីដែលស្ថិតនៅឃុំក្របៅ និងឃុំក្រញូង ឲ្យទៅក្រុមហ៊ុនមួយក្នុងតម្លៃ ៤៥០០$ក្នុងមួយហិកតា ដោយឲ្យខ្លួនគ្រាន់តែឈរឈ្មោះប៉ុណ្ណោះ រាល់ការទិញរៀបចំឯកសារគឺឈ្មោះនេះជាអ្នករៀបចំ។ ឯខ្លួនគេហៅចូលរួមពេលទៅទទួលសែកពីម្ចាស់លុយដោយឲ្យខ្លួនផ្តិតមេដៃដឹងលឺដែរ។ កន្លងមកឈ្មោះ [redacted] រចនា ធ្លាប់សន្យាជាមួយខ្លួនថា ជាអ្នកទទួលខុសត្រូវទាំងស្រុងតែម្នាក់ឯងដោយពុំឲ្យខ្លួនពាក់ព័ន្ធឡើយ។ ដូចមានក្នុងលិខិតបញ្ជាក់របស់ឈ្មោះ ម៉ាន់ រចនា ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ ស្រាប់។

-លោកស្រី [redacted] ណារី ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីកត់សម្គាល់ថា៖ ខ្លួនមានចំណុចកត់សម្គាល់មួយចំនួនពាក់ព័ន្ធនឹងករណីនេះ ឃើញថា ភាគីជនជាប់ចោទទាំងបួនមិនបានប្តឹងឧទ្ធរណ៍ទេ ចំណែកភាគីខាងដើមបណ្តឹងក៏មិនបានប្តឹងឧទ្ធរណ៍ក្នុងរឿងនេះដែរ ប៉ុន្តែអ្វីដែលសំខាន់ គឺ

**ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ** គាត់បានជួយប្ដឹងឧទ្ធរណ៍ត្រង់ចំណុចៈ **២-៣ និង ២-៤ នៃសេចក្ដីសម្រេច** ដែលសាលាដំបូងសម្រេចផ្ដន្ទាទោសជនជាប់ចោទចំនួនពីររូបមានស្ថានសម្រាលពេក ដោយសម្រេចការផ្ដន្ទាទោសព្យួរលើជនជាប់ចោទឈ្មោះ [redacted] **សារន់** និងឈ្មោះ [redacted] **សុខុម**។ ខ្លួនសុំកត់សម្គាល់ជម្រាបជូនអង្គសវនាការថា រឿងនេះជនជាប់ចោទទាំងប្អូនមិនបានចូលរួមនៅក្នុងដំណើរការនីតិវិធីសាលាដំបូងទេ មកដល់ពេលនេះក៏គាត់មិនបានចូលរួមដែរ នៅពេលដែលមិនបានចូលច្រើនដង គឺគាត់តែងតែផ្លាស់ប្ដូរមេធាវីជាបន្តបន្ទាប់ ដើម្បីពន្យារពេលសវនាការ និងមានការស្នើសុំធ្វើការពិភាក្សាចរចាជាមួយភាគីកូនក្ដីខ្លួន តែគាត់បែរជាគេចវេះសវនាការទៅវិញ។ ពាក់ព័ន្ធចំណុចមួយទៀត អង្គហេតុនេះហាក់បីដូចជាមានចេតនាទុច្ចរិតមុនបានទ្រព្យរបស់អ្នកដទៃ ដោយសារជនជាប់ចោទទាំងប្អូននេះ គឺមានពីរនាក់ ជាមន្ត្រីរាជការ ដោយឈ្មោះ [redacted] **សារន់** ជាប្រធានការិយាល័យភូមិបាលស្រុកកំចាយមារ និងឈ្មោះ [redacted] **សុខុម** ជាអធិការ។ ឃើញថា គាត់ទាំងពីរនាក់នេះមានតួនាទីជាមន្ត្រីរាជការនៅក្នុងមូលដ្ឋាននេះស្រាប់ ហើយមកដល់ពេលនេះដីដែលមានក្នុងកិច្ចព្រមព្រៀង គឺកូនក្ដីខ្លួនមិនទាន់បានទទួលសូម្បីតែបន្តិច ដែលចំណាយរហូតដល់ទៅជាង ២ លាន ដុល្លារអាមេរិក។

ខ្លួនសូមជម្រាបជូនអង្គសវនាការថា ចំពោះកិច្ចព្រមព្រៀង និងកិច្ចព្រមព្រៀងបន្ថែមដូចមានជាឯកសារក្នុងសំណុំរឿង គឺជនជាប់ចោទទាំងប្អូនជាអ្នកធ្វើជាមួយកូនក្ដីខ្លួន ហើយខ្លឹមសារក្នុងកិច្ចព្រមព្រៀងទាំងពីរនេះ គាត់បានអះអាងថាដីទាំងអស់ដែលមានទំហំដូចក្នុងកិច្ចព្រមព្រៀង គឺជាដីរបស់គាត់ផ្ទាល់ គាត់មិនបានអះអាងថា ជាដីរបស់ប្រជាពលរដ្ឋទេ ប៉ុន្តែឃើញថា ពាក់ព័ន្ធជាមួយការប្រគល់ប្រាក់តាមដំណាក់កាល មានជាមូលប្បទានប័ត្រ និងជាលិខិតប្រគល់-ទទួលជាច្រើនលើក ក្នុងនោះគាត់បានអូសប្រជាពលរដ្ឋមួយចំនួនឱ្យប្រគល់លុយក្នុងនោះដែរ ប៉ុន្តែក្នុងខ្លឹមសារនៃកិច្ចព្រមព្រៀងទាំងពីរ គឺគាត់អះអាងថា ជាដីរបស់គាត់មិនមែនជាដីរបស់ប្រជាពលរដ្ឋទេ។ នៅក្នុងរឿងនេះ កូនក្ដីខ្លួនបានចុះទៅទីតាំងនេះផ្ទាល់ហើយមានការតវ៉ាពីប្រជាពលរដ្ឋ ដោយសារប្រជាពលរដ្ឋបានអះអាងថា ប្រាក់ដែលទទួលពីជនជាប់ចោទទាំងប្អូន បានតែប្រាក់កក់ចំនួន **២០ (ម្ភៃ) ដុល្លារអាមេរិក** អីទេ ហេតុនេះហើយទើបមានការប្ដឹងផ្ដល់ ហើយជនជាប់ចោទមានការគេចវេះ ចំណែកកូនក្ដីខ្លួនបានអញ្ជើញគាត់មកធ្វើការដោះស្រាយ តែគាត់មិនបានដោះស្រាយរហូតដល់កូនក្ដីខ្លួនប្ដឹងមកតុលាការតែម្ដង។

**-តំណាងមហាអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា៖** ឃើញថា នៅក្នុងសំណុំរឿងនេះ ជនជាប់ចោទឈ្មោះ [redacted] **សារន់** និងឈ្មោះ [redacted] **សុខុម** ត្រូវជាប់ចោទពីបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅចំណុចភូមិចំការចេក១ ឃុំក្រញូង និងភូមិព្រៃទួលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង កាលពីអំឡុងថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨។ យល់ឃើញថា ក្នុងសំណុំរឿងនេះ ជាពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ **ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ** សុំប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ **២៧៣៨ "ល"ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២** របស់សាលាដំបូងរាជធានីភ្នំពេញ **ត្រង់ចំណុចៈ ២-៣ និង ២-៤ នៃសេចក្ដីសម្រេច** ដោយហេតុថា ជនជាប់ចោទឈ្មោះ [redacted] **សារន់** និងឈ្មោះ [redacted] **សុខុម** ជាមន្ត្រីរាជការ ដែលមានមុខងារជួយការងារប្រជាពលរដ្ឋ តែពួកគាត់បែរជាប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ បទ **រំលោភលើទំនុកចិត្ត**។ ដូចនេះ តំណាងមហាអយ្យការ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះពិនិត្យពិចារណា និងកែប្រែចំណុចទណ្ឌកម្មទោសព្យួរ មកជាទោសផ្ដន្ទាទោសដាក់ពន្ធនាគារវិញ។

-លោកស្រី [redacted] ណារី ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីសន្និដ្ឋានថា៖ ចំពោះអង្គហេតុនៃរឿងនេះ ឃើញថា កូនក្តីខ្លួនទាំងបួនបានចុះកិច្ចព្រមព្រៀងជាមួយជនជាប់ចោទទាំងបួន ដែលមានកិច្ចព្រមព្រៀងចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ និងកិច្ចព្រមព្រៀងបន្ថែមចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ហើយកិច្ចព្រមព្រៀងនេះទាក់ទងជាមួយនឹងការទិញដីទំហំសរុបចំនួន **៤១០,៤៦ (បួនរយដប់ក្បៀសសែសិបប្រាំមួយ) ហិកតា** ហើយការប្រគល់ប្រាក់របស់កូនក្តីខ្លួន គឺគាត់បានប្រគល់ប្រាក់ទៅឱ្យជនជាប់ចោទចំនួន **២.០៣១.៣៨២ (ពីរលានសូន្យសែនបីម៉ឺនមួយពាន់បីរយប៉ែតសិបពីរ) ដុល្លារអាមេរិក** តែកូនក្តីខ្លួនពុំទាន់បានទទួលដីសោះឡើយ រហូតមកដល់ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ ទើបដឹងថាមិនមានដីឱ្យកូនក្តីខ្លួន ហើយគាត់ចេះតែគេចវេះ ទើបកូនក្តីខ្លួនប្តឹងមកតុលាការតែម្តង។

ចំពោះកិច្ចព្រមព្រៀងទាំងពីរខាងលើ គឺជនជាប់ចោទទាំងបួនបានអះអាងថា ជាដីរបស់គាត់ ហើយបានយកប្រាក់ពីកូនក្តីខ្លួនមានចំនួនសរុបខាងលើ តែមិនមានដីឱ្យកូនក្តីខ្លួនសូម្បីតែមួយដុំឡើយ ក្នុងករណីនេះគាត់មានការគេចវេះថែមទៀតផង។ ឃើញថា នីតិវិធីរបស់សាលាដំបូងបានធ្វើការផ្តន្ទាទោសជនជាប់ចោទទាំងពីររូបនេះ មានលក្ខណៈស្រាលណាស់ ព្រោះជនជាប់ចោទទាំងពីររូបនេះជាមន្ត្រីរាជការ គាត់បានយកតួនាទីមកបោកប្រាស់ប្រជាពលរដ្ឋ ធ្វើឱ្យប្រជាពលរដ្ឋមានការជឿជាក់រហូតដល់កូនក្តីខ្លួនដែលជាអ្នករកស៊ីបានខូចខាតប្រាក់ជាច្រើនហើយទីបញ្ចប់មិនទទួលបានដីទាល់តែសោះ។

ចំពោះនីតិវិធីនៃការជំនុំជម្រះនៅដំណាក់កាលសាលាដំបូង ឃើញថា ជនជាប់ចោទមិនបានចូលរួមទេ ចេះតែពន្យារពេលសវនាការ ដើម្បីផ្លាស់ប្តូរមេធាវីជាបន្តបន្ទាប់ ហើយនៅចំណុចចុងក្រោយ គាត់ថានឹងធ្វើការចរចាជាមួយខាងកូនក្តីខ្លួន តែដើម្បីអូសបន្លាយពេលវេលា។ មកដល់ថ្ងៃនេះក៏គាត់នៅតែមិនព្រមចូល នេះជាករណីមួយដែលឃើញថា ជាអ្នកចេះដឹងតែគាត់មិនគោរពជាមួយនឹងភាពស្មោះត្រង់ក៏ដូចជាតួនាទីរបស់គាត់ជាមន្ត្រីរាជការ ដែលបម្រើផលប្រយោជន៍ប្រជាពលរដ្ឋនៅក្នុងទីតាំងនេះ ធ្វើឱ្យឃើញថា គាត់បោកប្រាស់ប្រជាពលរដ្ឋមួយចំនួន ដែលប្រជាពលរដ្ឋខ្លះមិនបានទទួលប្រាក់ពីគាត់វិញឡើយ។ ឃើញថាបញ្ហាទាំងនេះធ្វើឱ្យបាត់ជំនឿលើប្រព័ន្ធតុលាការថែមទៀតផង ដោយសារជននេះនៅតែអាចដើរសេរីភាពខាងក្រៅ ជាពិសេសគាត់នៅតែអាចប្រកបមុខរបរជាមន្ត្រីរាជការដដែល។

ខ្លួនសុំកត់សម្គាល់នៅក្នុងនីតិវិធីដើម ឃើញថាឈ្មោះ [redacted] សារន់ មុខរបរជា ប្រធានការិយាល័យ បានចេញប្រកាសបិទផ្សាយមួយទាក់ទងនឹងដីដែលមានលិខិតលេខ ៣០ ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២០ ដែលការចេញលិខិតនេះ គឺដើម្បីឱ្យមានការដោះបន្ទុកខ្លួនឯង ប៉ុន្តែតួនាទីរបស់គាត់មិនត្រូវបានប្រើក្នុងករណីនេះទេ។

ពាក់ព័ន្ធជាមួយនឹងទណ្ឌកម្មឃើញថា ពិតជាមានលក្ខណៈស្រាល ដែលភាគីមិនបានចូលរួមនីតិវិធី ហើយត្រូវបានសាលាដំបូងសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សារន់ និងឈ្មោះ [redacted] សុខុម ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល **០១ (មួយ) ឆ្នាំ តែទោសនេះត្រូវព្យួរធម្មតា** ចំណែកកូនក្តីខ្លួននាពេលនេះបានបាត់បង់ប្រាក់ និងដីសូម្បីតែមួយកន្លែងក៏មិនបានទទួលដែរ។



Scanned with CamScanner

អាស្រ័យហេតុនេះ ក្នុងនាមខ្លួនជាមេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះធ្វើការសម្រេចផ្តន្ទាទោសជនជាប់ចោទដល់អតិបរមានៃច្បាប់ ជាពិសេសទាក់ទងជាមួយនឹងការបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទផងដែរ ដើម្បីជាផលប្រយោជន៍ដល់កូនក្តីខ្លួន ក៏ដូចជាប្រជាពលរដ្ឋ ផ្តល់ភាពយុត្តិធម៌ជូនប្រជាពលរដ្ឋ និងដើម្បីកុំឱ្យជននេះចេះតែបង្កចលាចលក្នុងភូមិស្រុកថែមទៀតផង។

-ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្តឹង

-ក្រោយពីបានពិនិត្យឯកសារពាក់ព័ន្ធ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍ភ្នំពេញ

## យល់ឃើញថា

១-សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ១៣០៣ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២២ របស់ **អគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ភ្នំពេញ** សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ **២៧៣៨ "ល" ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២** របស់សាលាដំបូងរាជធានីភ្នំពេញ **ត្រង់ចំណុច: ២-៣ និង ២-៤ នៃសេចក្តីសម្រេចពុំគប្បីសម្រេចការផ្តន្ទាទោសព្យួរឡើយ។ ត្រូវអនុវត្តទោសដោយគ្មានការព្យួរទោស។** បានធ្វើឡើងត្រឹមត្រូវក្នុងកំណត់ច្បាប់ សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញទទួលសំណុំរឿងនេះជំនុំជម្រះបាន យោងតាមមាត្រា ៤៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] សារង់ បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា ខ្លួនបានចូលរួមជាក្រុមក្នុងការទិញដីឱ្យក្រុមហ៊ុនជាមួយឈ្មោះ [redacted] រចនា ដែរដោយគ្រាន់តែឈរឈ្មោះ ហើយខ្លួនពុំបានចុះទៅវាស់វែង ឬទៅធ្វើការទិញពីម្ចាស់ដីផ្ទាល់ទេ ខ្លួនគ្រាន់តែធ្លាប់បានទៅទទួលសែកពីក្រុមហ៊ុនប៉ុណ្ណោះ ។ ចំនួនលុយសរុបដែលក្រុមហ៊ុនទូទាត់ឱ្យជាសែកសរុបប្រហែល ២លានដុល្លារ ដោយតម្រូវឱ្យទិញដីជាង៣០០ហិកតាពេលនោះគឺ១ហិកតា ៤៥០០ដុល្លារ តែការទិញជាក់ស្តែងបានតែប្រហែល ១០៧ ហិកតាប៉ុណ្ណោះក៏អស់លុយ មូលហេតុដែលទិញដីមិនគ្រប់តាមកិច្ចព្រមព្រៀងដោយការតែដីឡើងថ្លៃជាបន្តបន្ទាប់ ហើយម្ចាស់លុយក៏បានឯកភាពទិញតាមលុយនោះដែរ ។

៣-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] សុខុម បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា ឈ្មោះ [redacted] រចនា បានបបួលខ្លួនឱ្យចូលរួមរៀបចំទិញដីដែលស្ថិតនៅឃុំក្រចៅ និងឃុំក្រញូង ឱ្យទៅក្រុមហ៊ុនមួយក្នុងតម្លៃ ៤៥០០$ក្នុងមួយហិកតា ដោយឱ្យខ្លួនគ្រាន់តែឈរឈ្មោះប៉ុណ្ណោះ រាល់ការទិញរៀបចំឯកសារគឺឈ្មោះនេះជាអ្នករៀបចំ។

**៤-តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖** ឃើញថា នៅក្នុងសំណុំរឿងនេះ ជនជាប់ចោទឈ្មោះ [redacted] សារង់ និងឈ្មោះ [redacted] សុខុម ត្រូវជាប់ចោទពីបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅចំណុចភូមិចំការ



Scanned with CamScanner

ចេក១ ឃុំក្រញូង និងភូមិព្រៃខ្វាលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង កាលពីអំឡុងថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨។ យល់ឃើញថា ក្នុងសំណុំរឿងនេះ ជាពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ **ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ** សុំប្តឹងឧទ្ធរណ៍នឹង សាលក្រមព្រហ្មទណ្ឌលេខ **២៧៣៨ "ល"ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២** របស់សាលាដំបូងរាជធានីភ្នំពេញ **ត្រង់ចំណុចៈ ២-៣ និង ២-៤ នៃសេចក្តីសម្រេច** ដោយហេតុថា ជនជាប់ចោទឈ្មោះ [redacted] សារន់ និងឈ្មោះ [redacted] សុខុម ជាមន្ត្រីរាជការ ដែលមានមុខងារជួយការងារប្រជាពលរដ្ឋ តែពួកគាត់បែរជាប្រព្រឹត្តបទល្មើស ព្រហ្មទណ្ឌ បទ ***រំលោភលើទំនុកចិត្ត***។ ដូចនេះ តំណាងមហាអយ្យការ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះពិនិត្យ ពិចារណា និងកែប្រែចំណុចទណ្ឌកម្មទោសព្យួរ មកជាទោសផ្តន្ទាទោសដាក់ពន្ធនាគារវិញ។

៥-មេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីសន្និដ្ឋានថា៖ ពាក់ព័ន្ធជាមួយ នឹងទណ្ឌកម្មឃើញថា ពិតជាមានលក្ខណៈស្រាល ដែលភាគីមិនបានចូលរួមនីតិវិធីហើយត្រូវបានសាលាដំបូង សម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សារន់ និងឈ្មោះ [redacted] សុខុម ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈ ពេល **០១ (មួយ) ឆ្នាំ តែទោសនេះត្រូវព្យួរទម្ងន់** ចំណែកកូនក្តីខ្លួននាពេលនេះ បានបាត់បង់ប្រាក់ និងដីសូម្បីតែ មួយកន្លែងក៏មិនបានទទួលដែរ។ ក្នុងនាមខ្លួនជាមេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំ ក្រុមប្រឹក្សាជំនុំជម្រះធ្វើការសម្រេចផ្តន្ទាទោសជនជាប់ចោទដល់អតិបរមានៃច្បាប់ ជាពិសេសទាក់ទងជាមួយ នឹងការបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទផងដែរ ដើម្បីជាផលប្រយោជន៍ដល់កូនក្តីខ្លួន ក៏ដូចជាប្រជាពលរដ្ឋ ផ្តល់ ភាពយុត្តិធម៌ជូនប្រជាពលរដ្ឋ និងដើម្បីកុំឱ្យជននេះចេះតែបង្កចលាចលក្នុងភូមិស្រុកថែមទៀតផង។

៦-សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញយល់ឃើញថាៈ តាមអំណានចម្លើយជនជាប់ចោទ តាមឯក សារភស្តុតាងនានាដែលមានក្នុងសំណុំរឿង មានពិរុទ្ធភាពដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] សារន់ និង ឈ្មោះ [redacted] សុខុម ពីបទ៖ ***រំលោភលើទំនុកចិត្ត*** ប្រព្រឹត្តនៅចំណុចភូមិចំការចេក១ ឃុំក្រញូង និងភូមិព្រៃខ្វាលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រម ព្រហ្មទណ្ឌ។

៧-សាលក្រមព្រហ្មទណ្ឌលេខ **២៧៣៨ "ល"ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២** របស់សាលាដំបូងរាជ ធានីភ្នំពេញ ដែលសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ ភ្នំពេញ សម្រេចតម្កល់សាលក្រមខាងលើនេះ ទុកជាបានការដដែល លើកលែងតែចំណុច **២.៣ និង ២.៤** នៃ សេចក្តីសម្រេច ស្តីពីទណ្ឌកម្មលើជនជាប់ចោទឈ្មោះ [redacted] សារន់ និងឈ្មោះ [redacted] សុខុម ត្រង់ចំណុចទោសព្យួរ គប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញសម្រេចបដិសេធចោលដោយហេតុថា ដោយហេតុថា ជនជាប់ ចោទឈ្មោះ [redacted] សារន់ និងឈ្មោះ [redacted] សុខុម ជាមន្ត្រីរាជការ ដែលមានមុខងារជួយការងារប្រជាពលរដ្ឋ តែពួក គាត់បែរជាប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ដែលបង្កឱ្យមានព្យសនកម្មធ្ងន់ធ្ងរដល់ជនរងគ្រោះ ដែលមិនគប្បីក្នុង ការផ្តល់នូវការព្យួរទោសនោះទេ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

**១.ទទួល** សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ **១៣០៣ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២២** របស់ **ឯកឧត្តមអគ្គព្រះរាជអាជ្ញារងសាលាឧទ្ធរណ៍ភ្នំពេញ** ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

**២.តម្កល់** សាលក្រមព្រហ្មទណ្ឌលេខ **២៧៣៨ "ល"ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២** របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល លើកលែងតែចំណុច **២.៣ និង ២.៤** នៃសេចក្តីសម្រេច ស្តីពីទណ្ឌកម្មលើជនជាប់ចោទឈ្មោះ[redacted]**សាវន់** និងឈ្មោះ [redacted]**សុខុម** ត្រង់ចំណុច **ទោសព្យួរ ត្រូវបដិសេធចោល** ដោយកែប្រែមកអនុវត្តទោសដាក់ពន្ធនាគារកំណត់រយៈពេល ០១ (**មួយ**) **ឆ្នាំ** វិញ។

ចំណុចផ្សេងពីនេះនៃសាលក្រមរក្សាទុកជាបានការដដែល។

សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣ កំបាំងមុខជនជាប់ចោទ ចំពោះមុខមេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣។

បើកសិទ្ធិប្តឹងទាស់ និងសាទុក្ខក្នុងកំណត់ច្បាប់។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

**"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"**

ថ្ងៃចន្ទ ២កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

សាលាឧទ្ធរណ៍ភ្នំពេញ,ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner